## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## សាររបស់ឯកឧត្តមឯកអគ្គរាជទូតគូម៉ាម៉ារូ យូជិ

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦

### សូមស្វាគមន៍ការហោះហើរត្រង់ពីប្រទេសជប៉ុន!!

នៅថ្ងៃទី១ ខែកញ្ញា ការហោះហើរត្រង់ជាប្រចាំរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា នឹងត្រូវបើកសម្ពោធ។ ក្រុមហ៊ុនហោះហើរ All Nippon Airways (ANA) នឹងចាប់ផ្ដើមការហោះហើរជាប្រចាំថ្ងៃរវាងទីក្រុងតូក្យូ និងទីក្រុងភ្នំពេញដែលនឹងនាំឲ្យប្រទេសជប៉ុនខិតមកកាន់តែជិតថែមមួយកំរិតទៀត។

ការហោះហើររវាងប្រទេសទាំងពីរគឺជាក្ដីស្រមៃដ៏ធំបំផុតរបស់ប្រជាជននៃប្រទេសទាំងពីរជាយូរមកហើយ។ ខ្ញុំមានក្ដីរីករាយដែលក្ដីស្រមៃនេះបានក្លាយទៅជាការពិតនៅទីបំផុត។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់គ្នារួមទាំងភាគីជប៉ុន និងភាគីកម្ពុជាដែលបានជួយឲ្យគម្រោងនេះកើតឡើង។

ខ្ញុំមានក្ដីជឿជាក់ថាការហោះហើរត្រង់ជារៀងរាល់ថ្ងៃរវាងទីក្រុងភ្នំពេញ និងទីក្រុងតូក្យូនឹងនាំឲ្យទំនាក់ទំនងទ្វេភាគីរបស់យើង រំកិលទៅកាន់កំរិតដ៏ថ្មីស្រឡាងមួយទៀត។ ចំនួនប្រជាជនដែលធ្វើដំណើរចុះឡើងរវាងប្រទេសយើងទាំងពីរនឹងកាន់តែច្រើន ទៅតាមគោលបំណងនៃការធ្វើដំណើររបស់ពួកគេ។

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅដល់លោកអ្នក ដែលអញ្ជើញទៅទស្សនកិច្ចនៅប្រទេសជប៉ុន រួមមានទាំងការសិក្សា បណ្ដុះបណ្ដាល អាជីវកម្ម ឬក៏ធ្វើដំណើរកំសាន្តផ្សេងៗ។ ក្រៅពីទីក្រុងតូក្យូ លោកអ្នកក៏អាចធ្វើដំណើរទស្សនកិច្ចទៅកាន់បណ្ដាទីក្រុងជាច្រើនទៀត តាមសេវាគមនាគមន៍ផ្សេងៗចេញពីទីក្រុងតូក្យូ ឬ ព្រលានយន្តហោះណារីតា។ លោកអ្នកនឹងមានការភ្ញាក់ផ្អើលដោយភាពខុសប្លែកនៃទីក្រុងទាំងនោះ។

ខ្ញុំសូមអោយប្រជាពលរដ្ឋកម្ពុជាស្វែងយល់អំពីប្រទេសខ្ញុំកាន់តែច្រើន។ ខ្ញុំជឿជាក់ថាដំណើរទស្សនកិច្ចរបស់លោកអ្នក នឹងជួយលោកអ្នកបង្កើតនូវទិដ្ឋភាពពិតប្រាកដមួយនៃប្រទេសរបស់ខ្ញុំ

ដែលជាពិសេសខ្ញុំសង្ឃឹមថាទាំងនោះគឺជាទិដ្ឋភាពមួយដ៏ល្អ។ នេះគឺជាមូលហេតុ ដែលធ្វើអោយខ្ញុំមានក្តីសប្បាយរីករាយយ៉ាងខ្លាំងអំពីការចាប់ផ្តើមនៃការហោះហើរត្រង់នេះ។

យើងខ្ញុំសូមស្វាគមន៍ដំណើរទៅកាន់ប្រទេសជប៉ុនរបស់លោកអ្នក!